**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ ១៤/២០០៧ កបធ.សសរ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៧

# សេចក្តីសម្រេច

## ស្តីពី

## របបប្រាក់សោធននិវត្តន៍ នៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៦/០២៥ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ
- យោងសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៧

**សម្រេច**

**ជំពូកទី១**

**ប្រាក់សោធននិវត្តន៍**

**ប្រការ១** : សមាជិកក្រុមប្រឹក្សាធម្មនុញ្ញទទួលប្រាក់សោធននិវត្តន៍បាន លុះត្រាតែបានបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោម :

- ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ គិតចាប់ពីឆ្នាំ ១៩៩៨ មក
- មានអាយុចាប់ពី ៦០ឆ្នាំឡើង
- មិនបានទទួលប្រាក់សោធននិវត្តន៍ពីស្ថាប័នណាមួយរបស់រដ្ឋទេ ។
- ត្រូវធ្វើពាក្យសុំចូលនិវត្តន៍

**ប្រការ២** : ប្រាក់សោធននិវត្តន៍ប្រចាំខែរបស់និវត្តជនម្នាក់ៗត្រូវផ្អែកលើប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាងនៃឆ្នាំដែលសមាជិកក្រុមប្រឹក្សាធម្មនុញ្ញបានទទួលខ្ពស់បំផុត ដោយគិតទាំងឋានៈមុខងារផងដែរ កំណត់ស្មើមួយរយភាគរយ ។

**ប្រការ៣** : ប្រាក់សោធននិវត្តន៍ប្រចាំខែត្រូវកំណត់ដោយផ្អែកលើរយៈពេលបំពេញការងារដូចតទៅ :

- ពី ១ឆ្នាំ ដល់ ៣ឆ្នាំ ទទួលបានសន្ទស្សន៍ 0.៥ %
- លើសពី ៣ឆ្នាំ ដល់ក្រោម ៦ឆ្នាំ ទទួលបានសន្ទស្សន៍ ១ %
- ពី ៦ឆ្នាំ ដល់ក្រោម ១១ឆ្នាំ ទទួលបានសន្ទស្សន៍ ២ %
- ពី ១១ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ ទទួលបានសន្ទស្សន៍ ៣ %
- ពី ១៦ឆ្នាំ ឡើងទៅ ទទួលបានសន្ទស្សន៍ ៤ %

ការគណនាប្រាក់សោធននិវត្តន៍ប្រចាំខែរបស់និវត្តជនត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម :

ប្រាក់សោធននិវត្តន៍ប្រចាំខែ = ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាងនៃឆ្នាំខ្ពស់បំផុត × សន្ទស្សន៍

ប្រាក់សោធននិវត្តន៍ប្រចាំខែអាចប្រែប្រួលបានទៅតាមប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភគ្រប់យ៉ាងនៃថវិកាប្រចាំឆ្នាំខ្ពស់បំផុត ដោយមិនគិតជានិវត្តជនមុន ឬ និវត្តជនក្រោយឡើយ ។

**ប្រការ៤** : និវត្តជនជាអតីតសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ នៅពេលជាប់ឆ្នោតជាតំណាងរាស្ត្រ ឬ សមាជិកព្រឹទ្ធសភា មិនត្រូវបានបើកផ្តល់ប្រាក់សោធននិវត្តន៍ទេ ។ សាមីជនត្រូវបើកប្រាក់បំណាច់ជាតំណាងរាស្ត្រ ឬ សមាជិកព្រឹទ្ធសភាជាធម្មតា ហើយនៅពេលចប់អាណត្តិទើបសាមីជនបើកប្រាក់សោធននិវត្តន៍វិញសារជាថ្មី ដោយកែសម្រួលសន្ទស្សន៍ទៅតាមអតីតភាព ។

**ប្រការ៥** : របៀបគិតអតីតភាពការងារ របស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ គឺមានដូចតទៅ :

- ត្រូវរាប់បញ្ចូលអតីតភាពការងារជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ នូវអតីតភាពការងារដែលនិវត្តជនបានធ្វើជាតំណាងរាស្ត្រ ឬ/និង សមាជិកព្រឹទ្ធសភា (ក្នុងករណីមានច្បាប់ស្តីពីសោធននិវត្តន៍ នៃសមាជិកព្រឹទ្ធសភា)
- មានអតីតភាព ចាប់ពី ១៦ថ្ងៃឡើងទៅ ត្រូវគិតស្មើ ១ខែ
- មានអតីតភាព ចាប់ពី ៦ខែឡើងទៅ ត្រូវគិតស្មើ ១ឆ្នាំ

## ជំពូកទី២

## ភារកិច្ច និងសមត្ថកិច្ចគ្រប់គ្រងប្រាក់សោធននិវត្តន៍

**ប្រការ៦** : ជារៀងរាល់ឆ្នាំ ក្រោមការណែនាំរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញត្រូវរៀបចំគម្រោងផែនការស្ថិតិ និងថវិកាប្រាក់សោធននិវត្តន៍ និងប្រាក់ធានារ៉ាប់រងសង្គមសម្រាប់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលគ្រប់ល័ក្ខខ័ណ្ឌចូលនិវត្តន៍ និងទទួលមរណភាព ដើម្បីដាក់ឆ្លងក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យសម្រេច បញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

**ប្រការ៧** : ការបើកប្រាក់សោធននិវត្តន៍ និងប្រាក់ធានារ៉ាប់រងសង្គមរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ធ្វើឡើងនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**ប្រការ៨** : សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីឆ្នាំ ២០០៨ តទៅ ។

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៊ិន ឈិន

__ចម្លងជូន__

- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ឯកសារ